# ភាកវតីជាតក



## ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ

## ជាតក ចតុក្កនិបាត កុដិទូសកវគ្គ

## បិដកលេខ ៥៨ ទំព័រ ២១៤

ដោយខេមរ អភិធម្មាវតារ

ព.ស. ២៥៦១

# កាកវតីជាតក[១]

## បុព្វហេតុនៃជាតក

*ព្រះសាស្តាកាលស្តេចគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុក (ចង់សឹក) មួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **វាតិ ចាយំ តតោ គន្ធោ** *(ក្លិនក្រអូបនេះក៏បក់មកអំពីទីនោះ) ដូច្នេះ (ជាដើម) ។*

*ពិតមែនហើយ ក្នុងកាលនោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកប្រាថ្នាចង់សឹកឬ ? ភិក្ខុនោះទូលទទួលថា ពិតហើយ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ព្រោះហេតុអ្វី អ្នកទើបចង់សឹក ? ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ព្រោះអំណាចកិលេស ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ មាតុគ្រាម ឈ្មោះថា ជាអ្នកដែលគេរក្សាទុកមិនបាន មិនអាចនឹងរក្សាបានឡើយ ក៏បុរាណបណ្ឌិតទាំងឡាយពីដើមក្នុងកាលមុន សូម្បីនឹងយកមាតុគ្រាមដាក់ទុកក្នុង***សិម្ពលិរុក្ខវិមាន** *(វិមានដែលនៅលើដើមរកា) ដែលនៅកណ្តាលមហាសមុទ្រហើយ ក៏មិនអាចនឹងរក្សាបានដែរ ហើយទ្រង់នាំយកអតីតនិទានមកជាសាធកៈដូចតទៅថា*

## អតីតនិទាន

**អតីតេ** *ក្នុងអតីតកាលដ៏យូរលង់ណាស់មកហើយ កាលព្រះបាទ***ព្រហ្មទត្ត***សោយរាជសម្បត្តិក្នុងនគរពារាណសី (ក្នុងកាលនោះ) ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តនោះ (ក្នុងកាលជាបន្តបន្ទាប់មក) ព្រះពោធិសត្វជាអ្នកដល់ព្រម*

---

*១. ជាកវតីជាតកនេះជាច្បាប់ឆដ្ឋសង្គាយនា តែច្បាប់ព្រះត្រៃបិដកខ្មែរ និងច្បាប់ខ្លះទៀតថា កាកាតិជាតក ។*

ដោយវ័យ ទ្រង់បានសោយរាជសម្បត្តិក្នុងកាលដែលព្រះរាជបិតាកន្ទង់ផុតទៅ ។ ព្រះអគ្គមហេសីរបស់ព្រះពោធិសត្វមានព្រះនាមថា **កាកវតី**[១] មានព្រះរូបឆោម លោមពណ៌ ស្រស់ឆើតឆាយ ហាក់បីដូចជាទេពអប្សរ (ក្នុងឋានសួគ៌ាល័យ) ។ នេះជាសាច់រឿងសង្ខេបក្នុងជាតកនេះ ចំណែកអតីតនិទានដោយពិស្តារនឹងប្រាកដជាក់ច្បាស់ក្នុងកុណាលជាតក[២] ។

ក្នុងកាលនោះ **សុបណ្ណរាជា** (ស្តេចគ្រុឌ) មួយអង្គ មកហើយដោយភេទជាមនុស្ស ។ កាលលេងនូវល្បែងបាសកា (ល្បែងដែលមានកូនសម្រាប់ដាក់វាយលេងលើគំនូសក្រឡាយ៉ាងដូចចត្រង្គជាដើម) ជាមួយនឹងព្រះរាជាពោធិសត្វ ក៏មានចិត្តប្រតិព័ទ្ធនឹងព្រះអគ្គមហេសីកាកវតី ទើបបានកាន់យកព្រះនាងនាំទៅកាន់**សុបណ្ណពិភព** ហើយអភិរម្យជាមួយនឹងព្រះនាងកាកវតីនោះ ។

ព្រះរាជាកាលមិនឃើញព្រះនាងទេវីទើបត្រាស់នឹងគន្ធព្វឈ្មោះ **នដកុវេរៈ** ថា អ្នកចូរស្វែងរកព្រះទេវី ។ នដកុវេរគន្ធព្វនោះ ទើបសង្កេតតាមដានស្តេចគ្រុឌនោះ បានទៅដេកនឹងព្រៃរំទឹកក្នុងស្រះមួយ ក្នុងវេលាដែលស្តេចគ្រុឌចេញអំពីស្រះនោះ បានទៅអង្គុយក្នុងចន្លោះនៃស្លាប កាលដល់ហើយ ក៏ចេញចាកចន្លោះនៃស្លាប ហើយបានធ្វើនូវកាយសំសគ្គៈ (ការស្ទាបអង្អែលកាយ) ដោយកិលេសជាមួយនឹងព្រះនាងកាកវតីនោះ រួចហើយក៏ចូលទៅដេកក្នុងចន្លោះនៃស្លាបរបស់ស្តេចគ្រុឌនោះម្តងទៀត បានមកហើយក្នុងដែលស្តេចគ្រុឌមកលេងបាសកានឹងព្រះរាជា ទើបកាន់យកពិណរបស់ខ្លួន មកកាន់ស្ថានទីលេងបាសកា ហើយឋិតនៅក្នុងសម្នាក់នៃព្រះរាជា ពោលនូវគាថាទីមួយដោយអំណាចនៃចម្រៀងថា

---

១. ច្បាប់ខ្លះថា កាកាតិ ហើយប្រហាក់ប្រហែលនឹងនាងកាកីដែរ ។ ២. បិដកលេខ ៦១ ទំព័រ ១៥៤។

វាតិ ចាយំ តតោ គន្ធោ		យត្ថ មេ វសតី បិយា
ទូរេ ឥតោ ហិ កាកាវតី[១]		យត្ថ មេ និរតោ មនោ។

*ស្ត្រីជាទីស្រឡាញ់របស់ទូលព្រះបង្គំនៅក្នុងទីណា ក្លិនក្រអូបនេះក៏បក់មកអំពីទីនោះ ចិត្តរបស់ទូលព្រះបង្គំត្រេកអរក្នុងស្ត្រីណា ស្ត្រីនោះឈ្មោះថានាងកាកវតី[១] ទៅនៅក្នុងទីឆ្ងាយ អំពីទីនេះ ។*

*បណ្ដាបទទាំងនោះ បទថាណ គន្ធោ (**ក្លិន**) បានដល់ ក្លិននៃរាងកាយរបស់ស្ត្រីនោះ ដែលលាបលនដោយក្លិនទិព្វ ។ បទថា យត្ថ មេ (**របស់ទូលព្រះបង្គំនៅក្នុងទីណា**) សេចក្ដីថា ស្ត្រីជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងសុបណ្ណពិភពណា អធិប្បាយថា ព្រះនាងធ្វើការស្ទាបអង្អែលកាយនឹងស្ដេចគ្រុឌនេះ ក្លិនរបស់នាងដែលជាប់មកនឹងកាយរបស់ស្ដេចគ្រុឌនេះ ទើបឈ្មោះថា បក់មកអំពីទីនោះ ។ បទថា ទូរេ ឥតោ (**នៅក្នុងទីឆ្ងាយអំពីទីនេះ**) បានដល់ ក្នុងទីឆ្ងាយអំពីទីនេះ ។ **ហិ** អក្សរត្រឹមតែជានិបាត ។ បទថា កាកាវតី បានដល់ ព្រះទេវីកាកវតីនោះ ។ បទថា យត្ថ មេ (**របស់ទូលព្រះបង្គំនៅក្នុងទីណា**) សេចក្ដីថា ចិត្តរបស់ខ្ញុំត្រេកអរ គឺមានតម្រេកហើយលើនាងណា ។*

*ស្ដេចគ្រុឌបានស្ដាប់ដូចនោះហើយ ទើបពោលគាថាទីពីរថា*

កថំ សមុទ្ទមតរី		កថំ អតរិ កេពុកំ
កថំ សត្ត សមុទ្ទានិ		កថំ សិម្ពលិមារុហិ។

---

*១. ច្បាប់បិដកខ្មែរថា កាកាតិ ។*

***អ្នកបានឆ្លងសមុទ្រ ដោយឧបាយដូចម្តេច បានឆ្លងទន្លេឈ្មោះកេបុកៈ ដោយឧបាយដូចម្តេច បានឆ្លងសមុទ្រទាំង ៧ ជាន់ ដោយឧបាយដូចម្តេច បានឡើងដើមរកា (ជាលំនៅរបស់យើង) ដោយឧបាយដូចម្តេច ។***

*គាថានោះមានសេចក្តីថា អ្នកឆ្លងសមុទ្រក្នុងជម្ពូទ្វីបនេះ និងទន្លេឈ្មោះកេបុកៈ ដែលនៅខាងមុខអំពីសមុទ្រនោះ និងឆ្លងសមុទ្រទាំង ៧ ដែលបិតនៅវាងភ្នំទាំងឡាយបានយ៉ាងណា គឺឆ្លងទៅបានដោយឧបាយដូចម្តេច ហើយអ្នកឡើងដើមសិម្ពលីដែលជាភពរបស់យើង ដែលបិតនៅដោយកន្លងហួសសមុទ្រទាំង ៧ នោះបានយ៉ាងណា ។*

*នដកុវេរគន្ធព្វបានស្តាប់ដូចនោះហើយទើបពោលគាថាទីបីថា*

តយា សមុទ្ទមតរឹ តយា អតរិ កេបុកំ

តយា សត្ត សមុទ្ទានិ តយា សិម្ពលិមារុហឹ។

***ខ្ញុំបានឆ្លងសមុទ្រជាមួយនឹងលោក បានឆ្លងទន្លេឈ្មោះកេបុកៈជាមួយនឹងលោក បានឆ្លងសមុទ្រទាំង ៧ ជាន់ជាមួយនឹងលោក បានឡើងដើមរកាជាមួយនឹងលោក ។***

*បណ្តាបទទាំងនោះ បទថា តយា (**ជាមួយនឹងលោក**) សេចក្តីថា ខ្ញុំអង្គុយនៅក្នុងវាងស្លាបរបស់លោក លោកធ្វើកិច្ចទាំងពួងនេះ ព្រោះលោកជាតួហេតុ ។*

*លំដាប់នោះ ស្តេចគ្រុឌបានពោលគាថាទីបួនថា*

ធិរត្ថុមំ មហាកាយំ ធិរត្ថុមំ អចេតនំ

យត្ថ ជាយាយហំ ជារំ អាវហាមិ វហាមិ ច។

អញនាំមក ទាំងនាំទៅ នូវសហាយរបស់ប្រពន្ធ ហេតុណា ហេតុនោះ គួរតិះដៀលខ្លួនអញមានកាយធំ គួរតិះដៀលខ្លួនអញដែលមិនមានគំនិត ។

បណ្តាបទទាំងនោះ បទថា ធិរត្ថុមំ (**គួរតិះដៀលខ្លួនអញ**) ស្តេចគ្រុឌកាលនឹងតិះដៀលខ្លួនឯង ទើបពោលឡើង ។ បទថា អចេតនំ (**មិនមានគំនិត**) បានដល់ ដែលឈ្មោះថា អ្នកមិនមានការគិត ព្រោះមិនដឹងការធ្ងន់និងស្រាល ព្រោះភាពជាអ្នកមានកាយធំ ។ បទថា យត្ថ កែថា យស្មា ប្រែថា ព្រោះហេតុណា ។ លោកពោលអធិប្បាយទុកថា ព្រោះហេតុដែលយើងនាំគន្ធព្វនេះដែលជាសហាយរបស់ភរិយានៃខ្លួន ដែលអង្គុយនៅក្នុងចន្លោះស្លាបមក ឈ្មោះថា នាំមក កាលនាំទៅ ឈ្មោះថា នាំទៅហើយ ដូច្នោះ គួរតិះដៀលខ្លួនឯង ។

ស្តេចគ្រុឌនោះបាននាំព្រះនាងកាកវតីនោះ មកថ្វាយព្រះចៅក្រុងពារាណសីហើយក៏លែងមកកាន់នគរនេះទៀត ។

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចធម៌ហើយប្រជុំជាតក ក្នុងវេលាចប់សច្ចធម៌ ភិក្ខុដែលអផ្សុកបានតាំងនៅក្នុងសោតាបត្តិផល ។

**តទា នដកុវេរោ ឧក្កណ្ឋិតភិក្ខុ អហោសិ** នដកុវេរគន្ធព្វក្នុងកាលនោះ បានមកជាភិក្ខុដែលអផ្សុកនេះ ។

**រាជា បន អហមេវ អហោសឹ** ចំណែកព្រះរាជាក្នុងកាលនោះ បានមកជាតថាគតនេះឯង ។

**កាកវតីជាតកវណ្ណនា និដ្ឋិតា។**

ការពណ៌នាកាកវតីជាតក ចប់ ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត កុដិទូសកវគ្គ បិដកលេខ ៥៨ ទំព័រ ២១៤)

ដោយខេមរ អភិធម្មាវតារ